

JOINT SDG FUND
USDA
USAID
ជំនួយពីពលរដ្ឋអាមេរិក
WFP

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែវិច្ឆិកា ឆ្នាំ២០២២

## ប្រទេសកម្ពុជា

### ផ្តោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលលោក លើ តម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


**ការិយាល័យទីផ្សារកសិកម្ម**
នាយកដ្ឋានផែនការនឹងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**អំឡុងពេលជាង៧ខែនៃជម្លោះអ៊ុយក្រែន** សង្គ្រាម និងការដាក់ទណ្ឌកម្មលើរុស្ស៊ីកំពុងធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូម អាសូត ផូស្វ័រ)។ រុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។

**សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO ក្នុងខែវិច្ឆិកា នៅថេរ ធៀបនឹងខែតុលា** និងតម្លៃធញ្ញជាតិរួមមាន៖ស្រូវសាឡី ពោត និងអង្ករ បានធ្លាក់ចុះបន្តិច ទំនងដោយសារគំនិតផ្តួចផ្តើមគ្រាប់ធញ្ញជាតិសមុទ្រខ្មៅត្រូវបានបន្តរយៈពេល ៤ខែទៀត។ ដោយសារផលវិបាកវិបត្តិសេដ្ឋកិច្ចសកល តម្លៃស្បៀងអាហារ តម្លៃថាមពល និងតម្លៃលោហៈមានតម្លៃ ត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះក្នុងឆ្នាំ ២០២៣ និង២០២៤ ប៉ុន្តែនៅតែខ្ពស់ជាងប្រវត្តិតម្លៃក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ។

**លទ្ធភាពទទួលបានជីកសិកម្មនឹងក្លាយជាបញ្ហាប្រឈមចម្បងនៅប៉ុន្មានខែខាងមុខ** ដោយសារជីកសិកម្មលើសកលលោកនៅតែមានតម្លៃខ្ពស់ក្នុងឆ្នាំ២០២២។ នេះទំនងជាមានឥទ្ធិពលខ្លាំងដល់ផលិតកម្មស្បៀងអាហារនៅជុំវិញពិភពលោកក្នុងឆ្នាំ២០២៣។ ផលិតកម្មស្រូវលើសកលលោកក្នុង ឆ្នាំ ២០២២/២០២៣ ត្រូវបានរំពឹងថានឹងថយចុះ ២,៤% ធៀបនឹងឆ្នាំ២០២១។ បញ្ហាគ្រោះមហន្តរាយពាក់ព័ន្ធនឹងធាតុអាកាសក្តៅខ្លាំងពេកនៅតំបន់ដាំដុះគ្រាប់ធញ្ញជាតិលើសកលលោកក្នុងខែវិច្ឆិកា ដែលជំរុញដោយអាកាសធាតុប្រែប្រួល បានដាក់សម្ពាធលើផលិតកម្ម និងតម្លៃនៃផលិតផលកសិកម្មលើសកលលោក។

**វិបត្តិស្បៀងអាហារពិភពលោក ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរមួយផ្នែក ដោយការរឹតបន្តឹងពាណិជ្ជកម្មស្បៀងអាហារ**ដែលដាក់ដោយប្រទេសមួយចំនួនដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។ គិតត្រឹមថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រទេសចំនួន ១៩ បានជំរុញឱ្យមានការហាមឃាត់ការនាំចេញអាហារចំនួន២៣ ហើយប្រទេសចំនួន ៨ បានអនុវត្តវិធានការកំណត់ការនាំចេញចំនួន ១២ ។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនៅទេ។** កូវីដ-១៩បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឲ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន-ធ្វើឲ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ ភស្តុតាងចង្អុលបង្ហាញពីស្ថានភាពសន្តិសុខស្បៀងដែលមិនស្ថិតស្ថេរក្នុងចំណោមគ្រួសារកម្ពុជា ជាពិសេសសម្រាប់អ្នកដែលងាយរងគ្រោះបំផុតនិងអ្នកដែលរស់នៅក្នុងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់

**ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កម្ពុជាជាប្រទេសប្រឈមខ្លាំងទៅនឹងការកើនឡើងតម្លៃថាមពល** ដោយសារតែការនាំចូលឥន្ធនៈខ្ពស់ធៀបនឹង GDP ការប្រើប្រាស់អគ្គិសនីក្នុងស្រុកនៅមានកម្រិត និងការពឹងលើឥន្ធនៈផូស៊ីល។ ជាការពិត ការឡើងថ្លៃប្រេង គួបផ្សំនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់កម្ពុជា ជាកត្តាសំខាន់រារាំងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលបានព្យាករនៅត្រឹម ៥.3% សម្រាប់ឆ្នាំ២០២២ និង៦,២% សម្រាប់ឆ្នាំ២០២៣។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានា ក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ (ឧបសម្ព័ន្ធទី១ និងទី២) នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្រ្ត)។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ២៥០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។

# មាតិកា


១. របកគំហើញសំខាន់ៗ ៣

២. លទ្ធផល
- ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ ៤
- ការទៅផ្សារ៖ទិន្នាការអតិថិជន ៥
- ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦
- ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧
- ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន ៨
- ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ៩
- ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ១០
- ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១១
- ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១២

៣. បរិបទ
- ពាណិជ្ជកម្ម ១៣
- ការឆ្លើយតបផ្នែកនយោបាយ ១៤

៤. វិធីសាស្រ្ត និងទីតាំងផ្សារ ១៥

៥. ឧបសម្ព័ន្ធទី១
- បម្រែបម្រួលថ្លៃលក់រាយ ១៦

៦. ឧបសម្ព័ន្ធទី២
- បម្រែបម្រួលថ្លៃលក់ដុំ ១៧

៧. ឧបសម្ព័ន្ធទី៣
- តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

| ២០២១ | ២០២២ |
| --- | --- |
| ៣,០% | ៥,៣%* |

**អតិផរណា**

| CPI កញ្ញា ២០២២ | CPI តុលា ២០២២ |
| --- | --- |
| ១៩៧,៤ | ១៩៧,៣ |

*ADB ព្យាករអត្រាអតិផរណានៅកម្ពុជាថាកើនដល់ ៥,០% នៅឆ្នាំ២០២២។ ក្នុងខែតុលា ឆ្នាំ២០២២ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម (CPI)** បានថយចុះ ០,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣,៦%ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ គ្រួសារ កម្ពុជាចំណាយស្ទើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ (៦០% សម្រាប់គ្រួសារក្រីក្រ) (CSES ២០១៩/២០)។*

**ការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី*
***CPI ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ មិនទាន់មាននៅឡើយទេ កំឡុងពេលរៀបចំរបាយការណ៍*




**[សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO (FFPI)](#)បង្ហាញនិន្នាការថេរក្នុងរយៈពេល ៣ខែចុងក្រោយ។** *ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ FFPI ស្មើនឹង ១៣៥,៧ ហើយវាបានថយចុះ ០,១% ធៀបនឹងខែមុន ប៉ុន្តែ នៅខ្ពស់ជាងឆ្នាំមុនក្នុងខែដូចគ្នាប្រមាណ ០,៣% ។ សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI)ក្នុងខែតុលា ឆ្នាំ២០២២ បានកើនឡើង ០,៣% ធៀបនឹងខែមុន និង៤,៥% ធៀបនឹងខែដដែលកាលពីឆ្នាំមុន។*




**តម្លៃលក់រាយប្រេងសាំង (ធម្មតា) និងប្រេងម៉ាស៊ូតបង្ហាញនិន្នាការថេរក្នុងខែវិច្ឆិកា ឆ្នាំ២០២២។** *តម្លៃលក់រាយប្រេងសាំង (ធម្មតា) បានកើនឡើងបន្តិច ២,០% និងប្រេងម៉ាស៊ូតក៏បានកើនបន្តិចដែរ ១,៣% ធៀបនឹងខែតុលា។ ទោះយ៉ាងណា បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុនវិញ តម្លៃប្រេងម៉ាស៊ូតនៅតែខ្ពស់ (+២៤,៧ %) ហើយប្រហែលនៅតែមានឥទ្ធិពលអវិជ្ជមានលើផលិតកម្ម និងតម្លៃស្បៀង។ ផ្ទុយទៅវិញ តម្លៃប្រេងសាំង បានថយចុះបន្តិច ៣,៧% បើធៀបនឹងឆ្នាំមុន។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ២០២២

# សង្ខេបរបកគំហើញសំខាន់ៗ

ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់ WFP ស្មើនឹង ១១១.៨៨៩ រៀល/ម្នាក់ ក្នុង១ខែ ស្មើនឹង ២៧,៣ ដុល្លារ បានថយចុះ ៤,០% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣,៨% ធៀបនឹងឆ្នាំមុន។ ការធ្លាក់ចុះនេះទំនងដោយសារ តម្លៃត្រកួនបានធ្លាក់ចុះ (១២,៧% ធៀបនឹងខែមុន) ដែលបណ្ដាលមកពីបានបំពេញស្តុកវិញ បន្ទាប់ពីប៉ះពាល់ដោយទឹកជំនន់ទ្រង់ទ្រាយធំក្នុងខែកញ្ញា/ដើមខែតុលា។ ជាមធ្យម តម្លៃកញ្ចប់ស្បៀងអាហារនៅទីប្រជុំជន (២៧,៤ ដុល្លារ៖ -៥,៣% MoM) ខ្ពស់ជាងនៅជនបទបន្តិច (២៧,២ ដុល្លារ៖ -២,១% MoM)។

ក្រៅពីត្រកួន តម្លៃស្បៀងអាហារភាគច្រើនក្នុងកញ្ចប់ស្បៀងអាហារក៏មានការប្រែប្រួលតិចតួច (±<៥,០% ធៀបនឹងខែមុន)។ ទោះបីជាមានការបន្ធូរបន្ថយតម្លៃស្បៀងអាហារមួយចំនួនធំ ក្នុងរយៈពេលមួយខែកន្លងមក ដែលប្រហែលបណ្ដាលមកពីស្ថិរភាពនៃតម្លៃប្រេងឥន្ធនៈ ក៏ទំនិញស្បៀងអាហារមួយចំនួននៅតែបង្ហាញពីការកើនឡើងនៃតម្លៃក្នុងរយៈពេលវែងរួមមាន៖ ស៊ុតទា (+១៩,៤ YoY) ត្រកួន (+១៦,១% YoY) ប្រេងឆា (+៨,៧% YoY) និងត្រីផ្ទក់ (+៦,២% YoY)។

ផ្សារបន្តមានដំណើរការល្អប្រសើរឡើង នៅក្នុងខែវិច្ឆិកា ដោយសន្ទស្សន៍ដំណើរការរបស់ផ្សារ (MFI) បានកើនឡើងដល់តម្លៃខ្ពស់បំផុតចាប់តាំងពីដើមឆ្នាំនេះ។ នេះត្រូវបានជំរុញដោយភាពប្រសើរឡើងនៃ ស្ថិរភាពនិងការអាចព្យាករណ៍របស់តម្លៃនៃមុខទំនិញសំខាន់ៗ ដែលទំនងដោយសារស្ថិរភាពនៃតម្លៃប្រេងឥន្ធនៈ។

តម្លៃប្រេងឥន្ធនៈនៅកម្ពុជាជាពិសេសប្រេងម៉ាស៊ូតក្នុងខែវិច្ឆិកា ឆ្នាំ២០២២ នៅតែមានតម្លៃខ្ពស់ដដែល បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ គួបផ្សំនឹងតម្លៃជីកសិកម្មដែលឡើងថ្លៃជាបន្តបន្ទាប់ ការផលិតស្បៀងអាហារក្នុងស្រុកនៅតែមានហានិភ័យក្នុងយៈពេលខាងមុខ។ ទិន្នន័យផ្លូវការបង្ហាញពីការថយចុះនៃផ្ទៃដីដាំដុះស្រូវរដូវវស្សាក្នុងឆ្នាំនេះចំនួន ៥% បើធៀបនឹងឆ្នាំ២០២១។ ភស្តុតាងពីការអង្កេតលើភាពងាយរងគ្រោះរបស់ WFP និងប្រភពដទៃទៀត បង្ហាញថា អត្រាភាពក្រីក្រកើនឡើង និងសន្តិសុខស្បៀងរបស់គ្រួសារមានស្ថានភាពអន់ថយយ៉ាងខ្លាំង នៅក្នុងឆ្នាំ២០២២ ។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដំណើរការរបស់ផ្សារបានបន្តប្រសើរឡើងដោយសារថេរភាព និងការអាចព្យាករណ៍បាននៃតម្លៃទំនិញសំខាន់ៗ ដែលទំនងដោយសារស្ថិរភាពនៃតម្លៃរបស់ប្រេងឥន្ធនៈ បានរួមចំណែកធ្វើឲ្យដំណើរការរបស់ផ្សារមានភាពល្អប្រសើរ។ ប្រធានផ្សារ/អ្នកលក់បានរាយការណ៍ថាគ្មានការកើនឡើងតម្លៃផ្គត់ផ្គង់ស្បៀងនោះទេ នៅក្នុងខែនេះ។




[1]សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។

# ការនៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្ដាផ្សារទាំង៥៦ (ផ្សារចំនួន១១ ទើបបន្ថែមក្នុងខែកញ្ញា) ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្ដីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្ដាហ៍ទី១ និងសប្ដាហ៍ទី៣ នៃខែនីមួយៗ។

បន្ទាប់ពីបានឈានដល់តម្លៃខ្ពស់បំផុតនៅចុងខែកញ្ញា ក្នុងពេលបុណ្យភ្ជុំបិណ្ឌ ចំនួនអតិថិជនដែលបានទៅផ្សារ ត្រូវបានរាយការណ៍ថាមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងដើមសប្ដាហ៍ដំបូងនៃខែវិច្ឆិកា។ ការកើនឡើងនេះទំនងជាដោយសារតែតម្រូវការរបស់អ្នកប្រើប្រាស់កើនឡើងក្នុងឱកាសបុណ្យអុំទូក ដែលប្រារព្ធពីថ្ងៃទី ០៧ ដល់ ០៩ ខែវិច្ឆិកា ឆ្នាំ ២០២២។ ទោះបីយ៉ាងណា ចំនួនអតិថិជន បានធ្លាក់ចុះតិចតួចនៅចុងខែវិច្ឆិកា ឆ្នាំ២០២២ ស្របតាមលំនាំដែលបានសង្កេតឃើញពេញមួយឆ្នាំថា ប្រជាជនអាចមានថវិកាតិចតួចក្នុងការចំណាយនៅចុងខែ។




បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងស៊េរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានធ្លាក់ចុះ ៤,០% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣,៨% ធៀបនឹងឆ្នាំមុន ដល់តម្លៃ ១១១.៨៨៩ រៀល/ម្នាក់/ខែ (ប្រហែល ២៧,៣ ដុល្លារ)។ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានមានតម្លៃខ្ពស់ជាងបន្តិចនៅទីប្រជុំជន (២៧,៤ ដុល្លារ) បើធៀបនឹងជនបទ (២៧,២ ដុល្លារ)។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិៈ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃខ្ពស់ជាងគេស្ថិតនៅផ្សារដងទង់ ក្នុងខេត្តកោះកុង និងសាមគ្គី ក្នុងខេត្តកំពត គឺ ១៣៦.៨៣៩ រៀល/ម្នាក់/ខែ (ប្រហែល ៣៣,៣ ដុល្លារ) (ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ២២,៣% )។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារលើ ក្នុងខេត្តសៀមរាប គឺ ៩០.៩៥០ រៀល/ម្នាក់/ខែ (ប្រហែល ២២,២ ដុល្លារ) (ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១៨,៧%)។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់ស្បៀងអាហារបម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ ចាប់ពី៥% ឬខ្ពស់ជាង ឡើងទៅ គឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ជាងនៅក្នុងផ្សារនៅជនបទ ។

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែវិច្ឆិកា ឆ្នាំ២០២២)**




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ០,០% | ១០០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ២០,០% | ៨០,០% |
| < ៥% ខ្ពស់ជាង | ៧១,៤% | ២៨,៦% |
| < ៥% ទាបជាង | ៥០,០% | ៥០,០% |
| ៥% ទៅ ១០% ទាបជាង | ៤៥,៥% | ៥៤,៥% |
| ≥ ១០% ទាបជាង | ១៦,៧% | ៨៣,៣% |

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ តម្លៃពងទាបានបង្ហាញពីនិន្នាការកើនឡើងដែលឈានដល់កម្រិតខ្ពស់បំផុត (៦.៣១៥ រៀល/១០គ្រាប់) សម្រាប់រយៈពេល ១១ ខែចុងក្រោយ គឺកើនឡើង ៣,៧% ធៀបនឹងខែមុន និង ១៩,៤% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ តម្លៃត្រកួនបានចាប់ផ្តើមថយចុះចំនួន ១២,៧% ធៀបនឹងខែមុន បន្ទាប់ពីបានកើនឡើងយ៉ាងខ្លាំងក្នុងខែតុលា ដែលអាចបណ្តាលមកពីគ្រោះទឹកជំនន់ដែលកើតឡើងក្នុងខែកញ្ញា និងដើមខែតុលា ប៉ុន្តែនៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១៦,១%។ តម្លៃអង្ករចម្រុះក្នុងខែវិច្ឆិកា ឆ្នាំ ២០២២ បន្តមានស្ថេរភាព (-០,៦% ធៀបនឹងខែមុន ប៉ុន្តែ +០,៣% ធៀបនឹងឆ្នាំមុន)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។

[2]ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។

# **ថ្នាក់ជាតិ៖** និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ តម្លៃសាច់ជ្រូក (-៤,៨%) ប្រេងឆា (-0,៨%) និងត្រីផ្ទក់ (+១,៤%) បានបង្ហាញការប្រែប្រួលបន្តិចបន្តួច (តិចជាង ៥%) បើធៀបនឹងខែមុន។ នេះទំនងដោយសារស្ថិរភាពនៃតម្លៃប្រេងឥន្ធនៈ ដែលនាំឱ្យថ្លៃដើមផលិតកម្ម និងតម្លៃនៃការដឹកជញ្ជូនស្បៀងអាហារនៅថេរ។ ទោះជាយ៉ាង តម្លៃប្រេងឆា និងត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ចំនួន ៨,៧% និង ៦,២% រៀងគ្នា ខណៈដែលតម្លៃសាច់ជ្រូកទាបជាងកាលឆ្នាំមុនចំនួន ១០,៤%។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




*[1] ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅខែវិច្ឆិកា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស្បៀងអាហារសំខាន់ៗភាគច្រើន លើកលែងត្រកួន និងប្រេងឆា នៅទីប្រជុំជនមានតម្លៃខ្ពស់ជាងនៅជនបទ (តារាង១)។

តម្លៃមធ្យមលក់រាយអង្ករចម្រុះ ត្រីផ្ទក់ និងប្រេងឆា ទាំងនៅទីប្រជុំជន និងទីជនបទ មានបម្រែបម្រួលតិចតួច (< ៥,០%) បើធៀបនឹងខែមុន។ ធៀបនឹងខែតុលា តម្លៃលក់រាយសាច់ជ្រូក តម្លៃលក់រាយត្រកួន និងតម្លៃលក់រាយជំឡូងផ្វាពណ៌លឿងបានថយចុះចំនួន ៥,៧% ៣,៥% និង៥,១% រៀងគ្នា នៅជនបទ ហើយក៏បានធ្លាក់ចុះចំនួន ៤,០% ១៨,២% និង ២,០% រៀងគ្នា នៅទីប្រជុំជនផងដែរ។ ផ្ទុយមកវិញ តម្លៃស៊ុតទាកើនឡើងចំនួន ៥,២% នៅជនបទ និង ២,៣% នៅទីប្រជុំជន ធៀបនឹងខែមុន។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.១០៤ | ២.០៩៤ |
| ត្រីផ្ទក់ (រស់) (គក) | ១០.៧២៤ | ១០.៦០១ |
| សាច់ជ្រូក (គក) | ១៧.២៩៤ | ១៦.៩៥២ |
| ស៊ុតទា (១០គ្រាប់) | ៦.៣៣០ | ៦.២៩០ |
| ប្រេងឆា (៥លីត្រ) | ៣១.៦២១ | ៣១.៩២០ |
| ត្រកួន (គក) | ៣.៨០៦ | ៣.៨៣៤ |
| ដំឡូងផ្វាពណ៌លឿង | ២.៦១២ | ២.២២៦ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែតុលា ឆ្នាំ២០២២ និងខែវិច្ឆិកា ឆ្នាំ២០២២

**ជនបទ**




**ទីប្រជុំជន**




***សម្គាល់៖** ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបចាប់ពីខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ មានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ ដែលនេះបណ្តាលមកពីទឹកភ្លៀងធ្លាក់ច្រើនជាងមធ្យមភាគច្រើនឆ្នាំនៅចុងខែកញ្ញា ដើមខែតុលា និងចុងខែវិច្ឆិកា (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ទោះបីជាអាកាសធាតុសើមបានបណ្តាលឱ្យមានលក្ខខណ្ឌអំណោយផល និងទឹកគ្រប់គ្រាន់សម្រាប់ផលិតផលកសិកម្មក៏ដោយ ក៏មានភ្លៀងធ្លាក់ខ្លាំងបណ្តាលឱ្យមានជំនន់ទឹកភ្លៀងភ្លាមៗនៅក្នុងតំបន់មួយចំនួននៃប្រទេសក្នុងខែកញ្ញា និងខែតុលា ដែលបានបង្កផលប៉ះពាល់ដល់ប្រជាជន និងកសិកម្ម។

ស្ថានភាពទឹកភ្លៀងលើសកម្រិតធម្មតានៅទូទាំងប្រទេសក្នុងខែវិច្ឆិកា លើកលែងតែភូមិភាគឦសានមានស្ថានភាពធម្មតា និងស្ងួត (ផែនទីខាងក្រោមខាងស្តាំ)។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | | ប្រមូលផល | | | | | | | | រៀបចំដី និងសាបព្រោះ | |
| ស្រូវរដូវវស្សា | ប្រមូលផល | | | | រៀបចំដី និងសាបព្រោះ | | ស្ទូង / ដាំដុះ | | | | ប្រមូលផល | |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី WFP Datavis*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែវិច្ឆិកា ឆ្នាំ២០២២




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# **ការតាមដានរដូវកាល៖** ស្ថានភាពរុក្ខជាតិ និងដំណាំ

ក្នុងខែវិច្ឆិកា ស្ថានភាពរុក្ខជាតិក្រោមកម្រិតធម្មតានៅបន្តមាននៅផ្នែកខ្លះនៃខេត្តជុំវិញបឹងទន្លេសាប (ឧ. ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ និងខេត្តសៀមរាប)។ ស្ថានភាពនេះទំនងបណ្តាលមកពីទឹកជំនន់ទឹកភ្លៀងក្នុងខែកញ្ញា/ខែតុលា។ យោងតាមរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខែតុលា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត ទឹកជំនន់បានបង្កផលប៉ះពាល់ដល់ផ្ទៃដីដាំដុះដំណាំកសិកម្មចំនួនប្រមាណ ២៨៨.៩៥៧ ហិកតា ហើយខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ បានរាយការណ៍ថាមានផ្ទៃដីប៉ះពាល់ធំជាងគេ។ ទោះយ៉ាងណា ស្ថានភាពរុក្ខជាតិនៅតំបន់ដទៃទៀតក្នុងប្រទេសកម្ពុជា នៅតែមានស្ថានភាពល្អប្រសើរ ដោយសារតែមានទឹកភ្លៀងគ្រប់គ្រាន់។

ដំណាំស្រូវរដូវវស្សាកំពុងប្រមូលផល ហើយគិតត្រឹមខែវិច្ឆិកា ស្រូវវស្សាប្រហែល ៨៨៩.០០០ ហិកតាត្រូវបានប្រមូលផលរួចរាល់ ហើយទទួលបានផលិតផលស្រូវ ស្មើនឹង ៣,២៧ លានតោន។ ទន្ទឹមនឹងនោះ ទឹកភ្លៀងច្រើនគ្រប់គាន់ក្នុងរយៈពេលបីខែចុងក្រោយ បានធ្វើឲ្យមានទឹកគ្រប់គ្រាន់បង្កលក្ខខណ្ឌអំណោយផលដល់ការដាំដុះស្រូវរដូវប្រាំង។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០២២ ការដាំដុះស្រូវរដូវប្រាំងសម្រេចបានប្រមាណ ១៩២.១០៩ ហិកតា ស្មើនឹង ៤០.៦% នៃផែនការជាតិប្រចាំឆ្នាំ នេះបើយោងតាមក្រសួងធនធានទឹក និងឧតុនិយម។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI) ក្នុងខែវិច្ឆិកា ឆ្នាំ២០២២**




*ប្រភព៖ FAO Global Information and Early Warning System.*

*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប់ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

ស្ថិតិសរុបនៃពាណិជ្ជកម្មនៅតែបង្ហាញវឌ្ឍនភាពជាវិជ្ជមាន។ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ២០,៨៦ ពាន់លានដុល្លារ ក្នុងរយៈពេល១១ខែដំបូងឆ្នាំ២០២២ ដែលខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ ១៨,១%។ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា ការនាំចេញអង្ករមានចំនួន ៥០៩.២៩៩ តោន (មានតម្លៃស្មើ ៣២៣,៩លានដុល្លារ) ក្នុងរយៈពេលដប់ខែដំបូងឆ្នាំ២០២២ បានកើនឡើង ១០,៧% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន។ បន្ថែមលើការនាំចេញអង្ករ ការនាំចេញស្រូវមានចំនួន ២,៩៤ លាន តោន (មានតម្លៃ៥៨៣,១៥ លានដុល្លារ) ក្នុងរយៈពេលដូចគ្នា។ ប្រទេសកម្ពុជាក៏បាននាំចេញ ប្រមាណ ៤,៦៧ លានតោន (+១០,៦% YoY) នៃផលិតផលកសិកម្មដទៃទៀតដូចជា៖ ដំឡូងមី ស្វាយចន្ទី ពោត សណ្តែកបាយ សណ្តែកសៀង ស្វាយ ម្រេច ដូងប្រេង ថ្នាំជក់ និងបន្លែ (របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខែតុលា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត)។

សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ចាប់ពីឆ្នាំ២០២៣ តទៅ រដ្ឋាភិបាលមានគោលបំណងនាំចេញអង្ករឱ្យបានយ៉ាងហោចណាស់ ១ លានតោនក្នុងមួយឆ្នាំ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២)។

ចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ ប្រទេសកម្ពុជាបាននាំចូលជាផ្លូវការសរុបមានតម្លៃ ២៧,៧៥ ពាន់លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៥២,៣ លាន ដុល្លារ (-៣៦,៩% ធៀបឆ្នាំមុន) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុងដែលអាចបរិភោគបានបន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វប្រេងរុក្ខជាតិ) ចំនួន ៩៧៣,៧ លាន ដុល្លារ (+១៥,៩%)។ ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្ម ចំនួន ២៤៥,៤ លាន ដុល្លារ (-៨,៨% ធៀបឆ្នាំមុន) គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២។

យោងតាម ការព្យាករណ៍ទីផ្សារផលិតផលរបស់ធនាគារពិភពលោក ដែលបានចេញផ្សាយក្នុងខែតុលា ឆ្នាំ២០២២ តម្លៃថាមពលលើសកលលោក ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ ១១% នៅឆ្នាំ២០២៣ និង១២%ទៀតនៅឆ្នាំ២០២៤ ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក តម្រូវការទាប និងការឆ្លើយតបនៃការផ្គត់ផ្គង់ ប៉ុន្តែតម្លៃនេះនៅតែខ្ពស់ជាងតម្លៃជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ការធ្លាក់ចុះតម្លៃថាមពលអាចបន្ធូរបន្ថយតម្លៃនៃអាហារ សម្ភារៈសម្រាប់កសិកម្មផ្សេងៗ និងការដឹកជញ្ជូន។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២២*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រប្រមាណ ៧០២.៩០៧ គ្រួសារ (ប្រមាណ ២,៨ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៨៦៨,៩២ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។

លើសពីនេះទៀត រដ្ឋាភិបាលបានអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ ដើម្បីកែលម្អលទ្ធភាពទទួលបានការថែទាំសុខភាព និងស្ថានភាពអាហារូបត្ថម្ភរបស់ពួកគេហើយ ចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២២ ស្ត្រីប្រហែល ១៨១.៥៤២ នាក់ និងកុមារ ១០៦.៨២០ នាក់ បានទទួលសាច់ប្រាក់សរុបចំនួន ២០,៥លានដុល្លារ។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

ក្រោមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១ - ២០២៣ របស់រដ្ឋាភិបាល ប្រាក់កម្ចីចំនួន ៣៥,៥៨ លានដុល្លារ ត្រូវបានផ្តល់សម្រាប់ការស្តារ និងលើកកម្ពស់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។

រដ្ឋាភិបាលកម្ពុជាបានបញ្ចេញថវិកាចំនួន ៩៣.០ លានដុល្លារអាមេរិក ដើម្បីរក្សាស្ថិរភាពតម្លៃស្រូវ តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុដល់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកែច្នៃ ដើម្បីទិញស្រូវពីកសិករក្នុងតម្លៃសមរម្យ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៥,២៣ លាននាក់ (៥០,៥% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៤% (៩៥,១៨% នៃប្រជាជនសរុប)។




*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២*




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២២*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្ដើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្ដាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្ដុះបណ្ដាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្ដង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៤ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្ដរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្ដប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្ដាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្ដាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្ដប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,099 | → -0.6% | → -0.8% | → 0.3% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,678 | → 1.4% | → 3.2% | ↑ 6.2% |
| ២.២ ត្រីប្រា(រស់) | Kg | 7,290 | → 3.5% | ↑ 8.7% | ↑ 15.0% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 7,896 | ↓ -5.3% | ↓ -8.3% | → 3.0% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 25,129 | → -2.3% | → -1.4% | → 3.0% |
| ២.៥ ប្រហុក | Kg | 10,242 | → -4.0% | ↓ -7.6% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 17,131 | → -4.8% | ↓ -11.8% | ↓ -10.4% |
| ៣.២ សាច់គោឃារ | Kg | 19,550 | → 2.5% | → -3.4% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,188 | → 3.7% | → 4.1% | ● |
| ៤.១ ស៊ុតទា | 10 eggs | 6,315 | → 3.7% | → 3.8% | ↑ 19.4% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,549 | → 2.1% | → 1.8% | ↑ 13.5% |
| ៥.១ ប្រេងឆា | 5 litres | 31,744 | → -0.8% | → -4.1% | ↑ 8.7% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,272 | → -2.9% | → 2.9% | ↑ 8.6% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,336 | ↓ -6.4% | ↑ 10.3% | ● |
| ៧.១ សណ្ដែកដី* | Kg | 10,073 | → 0.6% | ↑ 11.1% | ↑ 5.2% |
| ៧.២ សណ្ដែកសៀង | Kg | 4,980 | ↓ -9.0% | ↓ -14.4% | ● |
| ៧.៣ សណ្ដែកខៀវ | Kg | 5,849 | → -1.3% | → -2.5% | ● |
| ៨.១ ត្រកួន | Kg | 3,815 | ↓ -12.7% | ↑ 11.8% | ↑ 16.1% |
| ៨.២ ការ៉ុត* | Kg | 3,568 | → -0.6% | → -0.2% | ↓ -7.5% |
| ៨.៣ ស្លឹកបាស* | Kg | 5,548 | ↑ 9.8% | ↑ 20.2% | → 4.3% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,248 | ↑ 6.7% | → 0.0% | ↓ -10.0% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 5,174 | ↓ -19.0% | → 1.8% | ↓ -6.8% |
| ៨.៦ ម្ទេសតឿ* | Kg | 4,669 | ↓ -17.8% | ↑ 5.5% | ↓ -11.9% |
| ៨.៧ ម្ទេសចង្អឹះ | Kg | 4,036 | ↓ -19.9% | → -0.9% | → -3.7% |
| ៨.៨ ម្ទេសខៀវ* | Kg | 4,202 | ↓ -11.2% | → 3.7% | ↓ -7.7% |
| ៨.៩ ផ្ទីដូង* | Kg | 5,401 | → -4.2% | ↑ 21.4% | ↑ 10.1% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 6,278 | ↑ 72.3% | → -0.9% | → -4.4% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 5,377 | ↑ 43.1% | → -3.9% | ↑ 16.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,958 | → -0.2% | ↑ 14.0% | → 0.3% |
| ៨.១៣ ឃ្លោក* | Kg | 3,044 | → 3.0% | ↑ 12.4% | ↑ 44.8% |
| ៨.១៤ ត្រឡាច | Kg | 3,421 | → -0.7% | ↑ 22.2% | ↑ 34.7% |
| ៨.១៥ ត្រប់វែង | Kg | 4,089 | ↑ 7.6% | ↑ 25.5% | ↑ 26.8% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 4,208 | ↑ 10.1% | ↑ 38.8% | ↑ 8.8% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,494 | ↓ -15.0% | ↓ -9.4% | → 2.2% |
| ៨.១៨ ននោងមូល | Kg | 3,659 | → -1.4% | ↑ 11.7% | ↑ 31.1% |
| ៨.១៩ ននោងជ្រុង* | Kg | 3,728 | → 0.7% | ↑ 13.7% | ↑ 20.9% |
| ៨.២០ ល្ពៅង* | Kg | 1,540 | → 4.8% | → 3.4% | ↑ 16.8% |
| ៨.២១ សណ្ដែកគួរ | Kg | 4,951 | ↑ 16.8% | ↑ 22.4% | ↑ 17.4% |
| ៨.២២ ត្រយូងចេក* | Kg | 2,341 | ↑ 5.4% | ↑ 11.4% | ↓ -9.9% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 8,342 | ↓ -15.1% | → -0.3% | ↓ -16.7% |
| ៨.២៤ ដើមខាត់ណា* | Kg | 6,375 | ↓ -13.1% | → -4.9% | ↓ -14.7% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,492 | → -1.7% | → -0.4% | ↑ 16.0% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,207 | → -2.1% | → -1.1% | ● |
| ៨.២៧ អំពិលទុំ | Kg | 4,429 | → -2.7% | → 4.6% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,128 | → 1.9% | ↓ -5.3% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 2,250 | ↓ -55.0% | ↓ -55.0% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,721 | → 2.9% | ↓ -16.4% | ● |
| ១១.១ កូកាកូឡា | 330 ml | 1,919 | → -1.0% | → -3.0% | ● |
| ៧.១ សាំងធម្មតា | litre | 4,353 | → 1.3% | ↓ -8.0% | ● |
| ៧.២ ម៉ាស៊ូត | litre | 5,000 | → 1.9% | → -0.8% | ● |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,684 | → -4.3% | → -0.8% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្ដែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្ដល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,933 | → -1.1% | → 0.9% | → -0.4% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,617 | → 2.4% | → 3.9% | ↑ 6.7% |
| ២.២ ត្រីប្រា(រស់) | Kg | 6,382 | → 3.0% | ↑ 9.8% | ↑ 12.4% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 7,031 | → -5.0% | ↓ -8.4% | → 1.1% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 23,295 | → -0.8% | → -0.8% | → 3.0% |
| ២.៥ ប្រហុក | Kg | 9,104 | → -4.0% | → 1.7% | • |
| ៣.១ សាច់ជ្រូកពងជាន់ | Kg | 15,730 | ↓ -5.2% | ↓ -11.4% | ↓ -10.8% |
| ៣.២ សាច់គោឃាវ | Kg | 17,925 | → 2.8% | → -0.6% | • |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 11,915 | → 4.9% | ↑ 10.8% | • |
| ៤.១ ស៊ុតទា | 10 eggs | 5,862 | → 4.7% | → 3.8% | ↑ 21.7% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,107 | → 3.6% | ↑ 6.2% | ↑ 14.9% |
| ៥.១ ប្រេងឆា | 5 litres | 30,610 | → -0.9% | → -3.6% | ↑ 7.0% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,013 | → -0.1% | → 0.5% | → 3.6% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 2,973 | → -0.4% | ↑ 16.4% | • |
| ៧.១ សណ្ដែកដី* | Kg | 9,128 | → 1.5% | ↑ 11.3% | → 0.8% |
| ៧.២ សណ្ដែកសៀង | Kg | 4,667 | ↓ -6.6% | ↓ -14.1% | • |
| ៧.៣ សណ្ដែកខៀវ | Kg | 5,374 | → 0.2% | → -0.8% | • |
| ៨.១ ត្រកួន | Kg | 3,114 | ↓ -17.3% | ↑ 9.1% | ↑ 12.0% |
| ៨.២ ការ៉ុត* | Kg | 2,912 | → -2.4% | → -1.7% | ↓ -11.9% |
| ៨.៣ ស្ពៃក្ដោបបាស* | Kg | 4,267 | ↑ 7.6% | ↑ 16.6% | → -3.4% |
| ៨.៤ ស្លឹកម្រុំ* | Kg | 4,409 | ↑ 14.3% | ↑ 8.2% | ↓ -14.7% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,408 | ↓ -19.3% | → 1.4% | ↓ -7.0% |
| ៨.៦ ស្ពៃតឿ* | Kg | 3,857 | ↓ -19.1% | → 3.4% | ↓ -15.4% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 3,267 | ↓ -22.6% | → -3.4% | ↓ -9.8% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,451 | ↓ -11.9% | → 3.1% | ↓ -10.9% |
| ៨.៩ ផ្កាដូង* | Kg | 4,278 | → -4.6% | ↑ 19.7% | ↑ 5.6% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 4,733 | ↑ 56.5% | ↓ -6.2% | ↓ -16.5% |
| ៨.១១ ត្រយលម្ពៅ* | Kg | 3,968 | ↑ 28.2% | ↓ -14.5% | → -2.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,358 | → -0.6% | ↑ 15.2% | → -0.2% |
| ៨.១៣ ឃ្លោក* | Kg | 2,363 | → -2.7% | ↑ 16.7% | ↑ 34.2% |
| ៨.១៤ ត្រឡាច | Kg | 2,823 | → 0.0% | ↑ 28.6% | ↑ 33.6% |
| ៨.១៥ ត្រប់វែង | Kg | 3,460 | ↑ 12.2% | ↑ 28.2% | ↑ 26.7% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,524 | ↑ 13.3% | ↑ 46.3% | ↑ 7.0% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,788 | ↓ -15.6% | ↓ -11.2% | → 1.0% |
| ៨.១៨ននោងមូល | Kg | 3,038 | → 4.0% | ↑ 15.3% | ↑ 28.8% |
| ៨.១៩ ននោងជ្រុង* | Kg | 3,068 | → 3.6% | ↑ 13.4% | ↑ 20.0% |
| ៨.២០ ល្ពៅខ្ទី* | Kg | 1,130 | ↑ 6.3% | → -0.7% | ↑ 15.3% |
| ៨.២១ សណ្ដែកគួរ | Kg | 4,232 | ↑ 23.2% | ↑ 25.5% | ↑ 17.1% |
| ៨.២២ ត្រយូងចេក* | Kg | 1,857 | ↑ 7.5% | ↑ 6.7% | ↓ -14.6% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 7,259 | ↓ -14.7% | → -1.1% | ↓ -19.7% |
| ៨.២៤ ដើមខាត់ណា* | Kg | 5,493 | ↓ -14.2% | ↓ -6.8% | ↓ -16.4% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 1,897 | ↓ -5.9% | → -3.1% | ↑ 8.6% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,530 | → -2.0% | → -0.8% | • |
| ៨.២៧ អំពិលទុំ | Kg | 3,762 | → -2.7% | → 3.1% | • |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,676 | ↑ 5.7% | ↓ -6.4% | • |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,750 | ↓ -61.1% | ↓ -58.8% | • |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,548 | ↑ 6.3% | ↓ -11.6% | • |
| ១១.១ កូកាកូឡា | 330 ml | 1,623 | → 0.5% | → -2.8% | • |
| ៧.១ សាំងធម្មតា | litre | 4,274 | → 2.8% | ↓ -8.3% | • |
| ៧.២ ម៉ាស៊ូត | litre | 4,949 | → 2.4% | → -0.5% | • |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,302 | → -3.3% | → 3.1% | • |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្ដែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្ដល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---:|---:|---:|---:|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,371 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.7 | 29,565 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 17.1 | 21,210 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 10.1 | 3,641 |
| Diary | Milk | ---NA--- | 7 | 12.0 | - | - |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 7.0 | 2,723 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.8 | 26,894 |
| Tuber | Sweet Potato | 8.25. ដំឡូងជ្វាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.5 | 1,486 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | - | - |
| Fruit | Banana | ---NA--- | 91 | 96.4 | - | - |
| | | **Total** | **1,937** | **950.6** | - | **111,889** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ ខែវិច្ឆិកា ឆ្នាំ២០២២ WFP ប្រចាំប្រទេសកម្ពុជា។*